**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១០៦៩៥ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៦

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំរដូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំរដូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ មានដូចតទៅ ÷

## I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ ÷

### ១- ការងារដាំដុះ ÷

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៩ ៥៨៦ហ.ត ស្មើនឹង ១០៤,៩៧%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៣៧ ៦២៩ហ.ត ស្មើនឹង ៥,១៧%។

### ២- ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៦ (ដូចមានតារាងជូនភ្ជាប់) ÷

ការងារប្រមូលផលស្រូវរដូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ១ ៨២២ ៦៥១ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៩ ៥៨៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៥ ២៨៦ ៥៦៤តោន លើសឆ្នាំមុន ៥០៥ ១៨៦តោន។ ទិន្នផលគិតជាមធ្យម ២,៩០០តោន/ហ.ត (សប្តាហ៍មុន ៣,០៨០តោន/ហ.ត) លើសឆ្នាំមុន ២២៧គ.ក្រ/ហ.ត។

## II. ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់) ÷

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ២៧៣ ៤៩៧ហ.ត តិចជាងឆ្នាំមុនចំនួន ១០០ ៤៤៧ហ.តក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន១០ ៦២៣ហ.តស្មើនឹង ៣,៨៨% និងដោយគ្រឿងយន្តចំនួន ២៦២ ៨៧៤ហ.តស្មើនឹង ៩៦,១២%
- សាបបានសរុបចំនួន ៣០៦ហ.ត តិចជាងឆ្នាំមុនចំនួន ៥១០ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ២២៨ ៩៨២ហ.ត ស្មើនឹង ៥២,៧៩%នៃផែនការ ៤៣៣ ៧៥៥ហ.ត តិចជាងឆ្នាំមុន ១០៥ ១៣៦ហ.ត មូលហេតុដោយទឹកស្រកយឺតហើយខេត្តខ្លះពុំទាន់បានអនុវត្តនៅឡើយ។

III. **ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ១៧ ៦២១ហ.ត ស្មើនឹង ២៤,០៦% នៃផែនការ ៧៣ ២៤៩ហ.ត តិចជាងឆ្នាំមុន ៩ ៧០១ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ២ ៩០៤ហ.ត ស្មើនឹង ២០,៥៧% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ២ ១៥៨ហ.ត។

IV. **សេចក្តីសន្និដ្ឋាន**

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន ២ ៥៩៩ ៥៨៦ហត ស្មើនឹង **១០៤,៩៧%** នៃផែនការ ២ ៤៧៦ ៤៤៦ហត លើសឆ្នាំមុនចំនួន ៣៧ ៦២៩ហត។ មកទល់ពេលនេះ ប្រជាកសិករបាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង **៧០,១១%** នៃផ្ទៃដីអនុវត្ត **២ ៥៩៩ ៥៨៦**ហត ដែលទទួលបានទិន្នផលគិតជាមធ្យម **២,៩០០តោន/ហ.ត** និងកំពុងខិតខំជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តណែនាំជាប្រចាំដល់ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត អង្គភាពជំនាញទាំងអស់ត្រូវចាត់វិធានការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាព ជំរុញការជីកស្តារស្រះប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ ព្រមទាំងយកចិត្តទុកដាក់បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន រួមទាំងសហគមន៍កសិកម្មផងដែរ ក្នុងក្របខ័ណ្ឌក្រុមការងារទី៩ ដែលបានឯកភាពគ្នាក្នុងអង្គប្រជុំកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ កន្លងទៅនេះ ដើម្បីរិះរកវិធានការតាមភារកិច្ចក្នុងការចូលរួមដោះស្រាយរាល់បញ្ហាប្រឈមលើការធ្លាក់ចុះតម្លៃស្រូវអង្ករនៅមូលដ្ឋាន។ ដោយឡែកក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | ផ្ទៃដីប្រមូលផល (ហត) | ទិន្នផល (តោន/ហ.ត) | បរិមាណផល (តោន) | ភាគរយ (%) | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 247,015 | 185,185 | 2.681 | 496,475 | 74.97 | 12-12-2016 |
| 02 | បាត់ដំបង | 289,567 | 159,005 | 3.090 | 491,325 | 54.91 | 13-12-2016 |
| 03 | កំពង់ចាម | 89,861 | 51,887 | 3.452 | 179,114 | 57.74 | 08-12-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 79,283 | 2.719 | 215,569 | 63.73 | 13-12-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 53,331 | 2.935 | 156,500 | 46.33 | 13-12-2016 |
| 06 | កំពង់ធំ | 215,526 | 158,429 | 2.605 | 412,675 | 73.51 | 12-12-2016 |
| 07 | កំពត | 138,388 | 68,532 | 3.160 | 216,561 | 49.52 | 12-12-2016 |
| 08 | កណ្តាល | 35,329 | 13,100 | 3.520 | 46,108 | 37.08 | 13-12-2016 |
| 09 | កោះកុង | 10,503 | 9,428 | 2.791 | 26,311 | 89.76 | 12-12-2016 |
| 10 | ក្រចេះ | 33,072 | 30,363 | 2.040 | 61,941 | 91.81 | 06-12-2016 |
| 11 | មណ្ឌលគីរី | 23,608 | 21,631 | 2.727 | 58,978 | 91.63 | 13-12-2016 |
| 12 | ភ្នំពេញ | 10,291 | 7,106 | 2.750 | 19,541 | 69.05 | 13-12-2016 |
| 13 | ព្រះវិហារ | 82,398 | 78,562 | 2.931 | 230,245 | 95.34 | 12-12-2017 |
| 14 | ព្រៃវែង | 270,111 | 213,828 | 3.052 | 652,535 | 79.16 | 12-12-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 97,058 | 3.123 | 303,112 | 83.68 | 13-12-2016 |
| 16 | រតនគីរី | 26,185 | 25,616 | 2.490 | 63,784 | 97.83 | 13-12-2016 |
| 17 | សៀមរាប | 186,735 | 144,210 | 2.627 | 378,821 | 77.23 | 13-12-2016 |
| 18 | ព្រះសីហនុ | 16,605 | 11,015 | 2.450 | 26,987 | 66.34 | 13-12-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 28,678 | 2.500 | 71,695 | 100.00 | 06-12-2016 |
| 20 | ស្វាយរៀង | 168,528 | 122,543 | 2.710 | 332,092 | 72.71 | 13-12-2016 |
| 21 | តាកែវ | 197,444 | 129,332 | 3.364 | 435,013 | 65.50 | 13-12-2016 |
| 22 | ឧត្តរមានជ័យ | 86,501 | 79,736 | 2.545 | 202,913 | 92.18 | 13-12-2016 |
| 23 | កែប | 3,597 | 2,887 | 3.250 | 9,383 | 80.26 | 13-12-2016 |
| 24 | ប៉ៃលិន | 5,825 | 2,956 | 2.700 | 7,981 | 50.75 | 13-12-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 48,950 | 3.900 | 190,905 | 62.51 | 13-12-2016 |
| សរុប | | **2,599,586** | **1,822,651** | **2.900** | **5,286,564** | **70.11** | |
| តួលេខសប្តាហ៍មុន | | **2,599,586** | **1,530,202** | **3.080** | **4,712,509** | **58.86** | |
| តួលេខឆ្នាំ២០១៥ | | **2,561,957** | **1,788,638** | **2.673** | **4,781,378** | **69.82** | |
| ប្រៀបធៀបឆ្នាំមុន | | **37,629** | **34,013** | **0.227** | **505,186** | **0.30** | |

បានឃើញនិងឯកភាព

ភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦

ជ-ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ជ.ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ សរុប (ហ.ត) | ផ្ទៃដីភ្ជួររាស់ គោ-ក្របី ហ.ត | ផ្ទៃដីភ្ជួររាស់ គោ-ក្របី % | ផ្ទៃដីភ្ជួររាស់ គ្រឿងយន្ត ហ.ត | ផ្ទៃដីភ្ជួររាស់ គ្រឿងយន្ត % | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) សន្ទូង | ផ្ទៃដីស្ទូង និងព្រោះ (ហត) ពង្រោះ | ផ្ទៃដីស្ទូង និងព្រោះ (ហត) សរុប | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 01 | បន្ទាយមានជ័យ | 17,870 | 18,340 | - | - | 18,340 | 100.00 | 1 | 30 | 17,184 | 17,214 | 96.33 | 12-12-2016 |
| 02 | បាត់ដំបង | 16,400 | 6,955 | - | - | 6,955 | 100.00 | - | - | 6,955 | 6,955 | 42.41 | 13-12-2016 |
| 03 | កំពង់ចាម | 42,000 | 27,032 | 7,515 | 27.80 | 19,517 | 72.20 | 110 | 781 | 21,715 | 22,496 | 53.56 | 08-12-2016 |
| 04 | កំពង់ឆ្នាំង | 30,700 | 8,312 | - | - | 8,312 | 100.00 | 67 | - | 8,245 | 8,245 | 26.86 | 12-12-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 27,695 | - | - | 27,695 | 100.00 | 12 | 142 | 27,553 | 27,695 | 76.93 | 12-12-2016 |
| 07 | កំពត | 7,000 | 4,746 | - | - | 4,746 | 100.00 | - | - | 4,746 | 4,746 | 67.80 | 12-12-2017 |
| 08 | កណ្តាល | 55,800 | 16,713 | 1,037 | 6.20 | 15,676 | 93.80 | - | - | 8,077 | 8,077 | 14.47 | 13-12-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 14,700 | 1,466 | 9.97 | 13,234 | 90.03 | 21 | 88 | 12,232 | 12,320 | 88.00 | 06-12-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | - | - | - | - | - | - | - | - | - | - | |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 45,104 | - | - | 45,104 | 100.00 | - | - | 45,104 | 45,104 | 60.14 | 12-12-2016 |
| 15 | ពោធិសាត់ | 9,000 | 8,780 | - | - | 8,780 | 100.00 | - | - | 7,774 | 7,774 | 86.38 | 13-12-2016 |
| 16 | រតនៈគិរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | 17,900 | - | - | 17,900 | 100.00 | 20 | 80 | 14,395 | 14,475 | 69.18 | 13-12-2016 |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 1,408 | - | - | 1,408 | 100.00 | - | - | 11,187 | 11,187 | 55.94 | 13-12-2016 |
| 21 | តាកែវ | 75,000 | 66,077 | 455 | 0.69 | 65,622 | 99.31 | - | - | 33,116 | 33,116 | 44.15 | 13-12-2016 |
| 22 | ឧត្តរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | 35 | - | - | 35 | 100.00 | - | - | 35 | 35 | 116.67 | 13-12-2016 |
| 24 | ប៉ៃលិន | 1,000 | 75 | | - | 75 | 100 | | | 63 | 63 | 6.30 | 13-12-2016 |
| 25 | ត្បូងឃ្មុំ | 10,500 | 9,625 | 150 | 1.56 | 9,475 | 98.44 | 75 | 750 | 8,730 | 9,480 | 90.29 | 13-12-2016 |
| | **សរុប** | **433,755** | **273,497** | **10,623** | **3.88** | **262,874** | **96.12** | **306** | **1,871** | **227,111** | **228,982** | **52.79** | |
| | **តួលេខសប្តាហ៍មុន** | **433,755** | **232,220** | **9,219** | **3.97** | **223,001** | **96.03** | **219** | **1,632** | **178,106** | **179,738** | **41.44** | |
| | **តួលេខឆ្នាំមុន** | **417,325** | **373,944** | **12,235** | **3.27** | **361,709** | **96.73** | **816** | **6,521** | **327,597** | **334,118** | **80.06** | |
| | **ប្រៀបធៀបឆ្នាំមុន** | **16,430** | **-100,447** | **-1,612** | **0.61** | **-98,835** | **-0.61** | **-510** | **-4,650** | **-100,486** | **-105,136** | | |

**បានឃើញនិងឯកភាព**
ជ- ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

រស់ សិរី

ភ្នំពេញ, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦
ជ. ប្រធានការិយាល័យស្ថិតិ

ឡូ វិញ្ញ:

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | | - | | - | | 110 | 105 | - | 35 | - | | 110 | 140 | 127.27 |
| 02 | បាត់ដំបង | 100 | 3 | | | 100 | 6 | 30 | 15 | | | | | 230 | 24 | 10.43 |
| 03 | កំពង់ចាម | 790 | 187 | - | - | 30 | 548 | 360 | 10 | - | - | 3,380 | 140 | 4,560 | 885 | 19.41 |
| 04 | កំពង់ឆ្នាំង | 80 | 38 | - | - | 760 | 231 | 60 | 27 | 10 | - | 60 | 5 | 970 | 301 | 31.03 |
| 05 | កំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| 06 | កំពង់ធំ | 199 | - | - | - | - | - | - | 36 | - | - | - | - | 199 | 36 | 18.09 |
| 07 | កំពត | 205 | | - | | 30 | | 235 | | - | | - | | 470 | - | - |
| 08 | កណ្តាល | 96 | - | 50 | - | 150 | - | 442 | 75 | - | - | - | - | 738 | 75 | 10.16 |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | 85 | - | - | - | - | 110 | 89 | - | - | - | 83 | 230 | 257 | 111.74 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | | - | | | | | | | | | | - | - | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | | - | | 1,025 | | 175 | | - | | - | | 1,330 | - | - |
| 15 | ពោធិ៍សាត់ | 550 | 5 | 50 | - | 200 | - | 720 | 31 | - | | - | | 1,520 | 36 | 2.37 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | - | 10 | 10 | 210 | - | 405 | 85 | - | - | - | - | 625 | 95 | 15.20 |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | 20 | - | | | | | 30 | | | | 10 | - | 60 | |
| 20 | ស្វាយរៀង | | | | | | | 523 | | | | | | 523 | - | - |
| 21 | តាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | 9 | - | - | - | - | 30 | 138 | - | | - | | 130 | 147 | 113.08 |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | 95 | - | - | - | 45 | 20 | 20 | - | - | 1,340 | 375 | 1,590 | 535 | 33.65 |
| | **សរុប** | **3,624** | **513** | **110** | **15** | **2,616** | **847** | **3,785** | **881** | **10** | **35** | **4,780** | **613** | **14,121** | **2,904** | **20.57** |
| | **តួលេខសប្តាហ៍មុន** | **3,624** | **386** | **110** | **15** | **2,616** | **680** | **3,785** | **784** | **10** | **35** | **4,780** | **138** | **14,121** | **2,038** | **14.43** |
| | **តួលេខឆ្នាំមុន** | **3,624** | **1,055** | **1,173** | **712** | **2,789** | **418** | **3,735** | **623** | **80** | **7** | **8,930** | **2,247** | **20,331** | **5,062** | **24.90** |
| | **ប្រៀបធៀបឆ្នាំមុន** | - | -542 | -1,063 | -697 | -173 | 429 | 50 | 258 | -70 | 28.00 | -4,150 | -1,634 | -6,210 | -2,158 | -4.33 |

**បានឃើញ និងឯកភាព**

ជ. ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៦

ជ. ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | 19 | - | 6,250 | 668 | - | - | 1,325 | 532 | 120 | 1 | 7,920 | 1,220 | 15.40 |
| 02 | បាត់ដំបង | 460 | - | 43 | - | - | - | 50 | 12 | 960 | 120 | 300 | | 1,770 | 175 | 9.89 |
| 03 | កំពង់ចាម | 1,010 | 150 | 1,459 | 521 | 20 | - | 760 | 147 | 2,380 | 1,857 | 150 | 507 | 4,320 | 3,970 | 91.90 |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | 127 | - | 90 | 36 | 230 | 75 | 1,860 | 645 | 1,800 | 677 | 5,070 | 1,560 | 30.77 |
| 05 | កំពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| 06 | កំពង់ធំ | 130 | - | 64 | - | 90 | - | 60 | 45 | 345 | 163 | 20 | - | 645 | 272 | 42.17 |
| 07 | កំពត | 200 | - | | | 135 | | 245 | | 590 | 40 | 255 | | 1,425 | 40 | 2.81 |
| 08 | កណ្តាល | 8,101 | 6,620 | 495 | 480 | 225 | - | 190 | - | 5,056 | 944 | 4,307 | 169 | 17,879 | 1,608 | 8.99 |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 1,160 | 934 | - | - | 80 | - | 420 | 192 | 40 | 38 | 2,340 | 1,390 | 59.40 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | 474 | - | | - | 474 | - |
| 12 | ភ្នំពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | | | 200 | | 10 | | 790 | | 1,425 | | 4,250 | - | - |
| 15 | ពោធិ៍សាត់ | 200 | 100 | 51 | - | 850 | 197 | 350 | - | 500 | 107 | 300 | 5 | 2,200 | 360 | 16.36 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | 155 | - | 2,490 | 415 | 265 | 130 | 2,040 | 530 | 1,850 | 85 | 7,475 | 1,315 | 17.59 |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | 2 | | | 370 | 2 | - |
| 19 | ស្ទឹងត្រែង | 250 | - | 104 | - | - | | - | 36 | 450 | 94 | 500 | 110 | 1,200 | 344 | 28.67 |
| 20 | ស្វាយរៀង | | | | | 7,100 | 368 | 110 | - | 1,170 | 874 | - | | 8,380 | 1,242 | 14.82 |
| 21 | តាកែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | 24 | 2 | 30 | 14 | 100 | 31 | 200 | 41 | - | | 480 | 110 | 22.92 |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | 2,410 | 2,245 | - | 20 | 400 | 215 | 1,145 | 530 | 490 | 290 | 10,977 | 3,465 | 15,257 |
| | **សរុប** | **18,713** | **12,595** | **4,108** | **1,937** | **19,521** | **3,416** | **2,585** | **873** | **11,350** | **7,457** | **12,067** | **1,787** | **73,249** | **17,621** | **24.06** |
| | **តួលេខសប្តាហ៍មុន** | **18,713** | **12,595** | **3,659** | **1,414** | **19,521** | **2,600** | **2,585** | **751** | **11,350** | **6,260** | **12,067** | **1,555** | **73,249** | **14,825** | **20.24** |
| | **តួលេខឆ្នាំមុន** | **10,504** | **188** | **9,352** | **6,827** | **4,174** | **4,335** | **4,116** | **1,107** | **11,804** | **7,523** | **12,100** | **5,005** | **42,698** | **27,322** | **63.99** |
| | **ប្រៀបធៀបឆ្នាំមុន** | **8,209** | **12,407** | **-5,244** | **-4,890** | **15,347** | **-919** | **-1,531** | **-234** | **-454** | **-66** | **-33** | **-3,218** | **30,551** | **-9,701** | **-39.93** |